# សេចក្តីប្រកាសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីស្ថានភាពនៅឧបទ្វីបកូរ៉េ
# ២៨ មេសា ២០១៧

អាស៊ានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការកើនឡើងនៃភាពតានតឹងនៅឧបទ្វីបកូរ៉េ រួមមានការសាកល្បងអាវុធនុយក្លេអ៊ែរទាំង២ លើក នៅឆ្នាំ២០១៦ និងការសាកល្បងមីស៊ីលចម្ងាយឆ្ងាយរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។

អាស៊ានគិតថាអស្ថិរភាពនៅឧបទ្វីបកូរ៉េ គឺប៉ះពាល់យ៉ាងខ្លាំងទៅលើតំបន់ និងពិភពលោក។

អាស៊ានជំរុញយ៉ាងខ្លាំងឲ្យសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ គោរពឲ្យបានពេញលេញនូវកាតព្វកិច្ចរបស់ខ្លួនដែលមានចែងក្នុងសេចក្តីសម្រេចពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ ក្នុងគោលដៅរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

អាស៊ានក៏ជំរុញឲ្យសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងភាគីពាក់ព័ន្ធទាំងអស់រក្សាភាពអត់ធ្មត់ដើម្បីបន្ធូរបន្ថយភាពតានតឹង និងបញ្ចៀសពីសកម្មភាពនានាដែលអាចធ្វើឲ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ។

អាស៊ានគាំទ្រដល់ការលុបបំបាត់អាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េ ក្នុងន័យនេះ អំពាវនាវឲ្យមានដំណើរការឡើងវិញនូវកិច្ចសន្ទនាស្តីពីឧបទ្វីបកូរ៉េដើម្បីបន្ធូរបន្ថយភាពតានតឹង និងបង្កបរិយាកាសអំណោយផលដល់សន្តិភាព និងស្ថិរភាព។